**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

**ឯកសារដើម**
**ORIGINAL/ORIGINAL**
ថ្ងៃ ខែ ឆ្នាំ (Date): 27-Dec-2021, 13:55
CMS/CFO: Sann Rada

**អង្គជំនុំជម្រះតុលាការកំពូល**
Supreme Court Chamber

Chambre de la Cour suprême

សំណុំរឿងលេខ: ០០៣/០៨-តុលា-២០២១-អ.វ.ត.ក/អ.ជ.ត.ក(០៥)

Case File/Dossier N°. 003/08-10-2021-ECCC/SC(05)

**នៅចំពោះមុខ៖**

**ចៅក្រម គង់ ស្រីម ប្រធាន**
**ចៅក្រម Chandra Nihal JAYASINGHE**
**ចៅក្រម សោម សិរីវឌ្ឍ**
**ចៅក្រម Florence Ndepele Mwachande MUMBA**
**ចៅក្រម ម៉ុង មុន្នីចរិយា**
**ចៅក្រម Maureen Harding CLARK**
**ចៅក្រម យ៉ា ណារិន**

**កាលបរិច្ឆេទឯកសារ៖** **ថ្ងៃទី ខែ ២៧ ធ្នូ ឆ្នាំ ២០២១**
**ភាសាដើម៖** **ខ្មែរ/អង់គ្លេស**
**ចំណាត់ថ្នាក់ឯកសារ៖** **សាធារណៈ**

# សេចក្ដីសម្រេចលើសំណើរបស់ មាស មុត សុំបញ្ចប់សំណុំរឿង ០០៣

**សហព្រះរាជអាជ្ញា**
Brenda J. HOLLIS
សហព្រះរាជអាជ្ញាអន្តរជាតិ

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី**
**ក្នុងសំណុំរឿង ០០៣ ទាំងអស់**

**ជនជាប់ចោទ**
មាស មុត

**សហមេធាវីជនជាប់ចោទ**
អាង ឧត្តម
Michael G. KARNAVAS

1. **អង្គជំនុំជម្រះតុលាការកំពូល**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យនៅចន្លោះពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ ("អង្គជំនុំជម្រះតុលាការកំពូល" ឬ"អង្គជំនុំជម្រះ" និង "អ.វ.ត.ក" នីមួយៗ)

2. **បានទទួល** "សំណើរបស់ មាស មុត សុំបញ្ចប់សំណុំរឿង ០០៣" ដែលមេធាវីការពារក្តីបានស្នើសុំឱ្យអង្គជំនុំជម្រះបញ្ចប់សំណុំរឿង ០០៣ និងបង្គាប់សហចៅក្រមស៊ើបអង្កេតរក្សាទុកសំណុំរឿងនេះក្នុងបណ្ណសារ ដោយផ្អែកលើមូលដ្ឋានថា ពុំមានដីកាបញ្ជូនទៅជំនុំជម្រះសុពលភាពក្នុងសំណុំរឿង ០០៣ និងថា មាស មុត មានសិទ្ធិទទួលបានចំណាត់ការស្មើភាពគ្នាចំពោះមុខច្បាប់ និងថា ពុំមានហេតុផលសមស្របដែលតម្រូវឱ្យពុំអនុវត្តតាមការយល់ឃើញរបស់អង្គជំនុំជម្រតុលាការកំពូលក្នុងសំណុំរឿង ០០៤/២ ដែលបានបញ្ចប់កិច្ចដំណើរការនីតិវិធីប្រហាក់ប្រហែលគ្នាដោយសារការចេញដីកាដំណោះស្រាយពីរ ដែលខុសច្បាប់ និងពុំមានមតិភាគច្រើនលើសលុប ដែលតម្កល់ ឬបដិសេធដីកាណាមួយនោះឡើយ ("សំណើសុំបញ្ចប់")[1]

3. **កត់សម្គាល់**លើសារណាតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិដែលថា សំណើរបស់ មាស មុត សុំបញ្ចប់ គប្បីត្រូវបដិសេធចោល ដោយសារពុំមានមូលដ្ឋានត្រឹមត្រូវ និងបានអះអាងថា "គោលការណ៍នៃស្មើភាពគ្នាពុំអាច និងពុំគប្បីត្រូវបានអនុវត្តធ្វើជាមូលដ្ឋានសម្រាប់បន្តកំហុសផ្នែកច្បាប់កន្លងមកឡើយ" និងថា "កំហុសផ្នែកច្បាប់ទាំងនេះបានផ្តល់ជាមូលហេតុសមស្របសម្រាប់ការពុំអនុវត្តតាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះក្នុងសំណុំរឿង ០០៤/២"[2]

4. **កត់សម្គាល់**លើការឆ្លើយតបរបស់ មាស មុត ដែលថា អំណះអំណាងរបស់សហព្រះរាជអាជ្ញាអន្តរជាតិ គប្បីត្រូវបានបដិសេធចោលដោយពុំចាំបាច់ពិនិត្យតទៅទៀត ដោយសារក្នុងចំណោមនោះ សហព្រះរាជអាជ្ញាអន្តរជាតិបានលើកអំណះអំណាងច្រំដែល ដែលពុំបានទទួលជោគជ័យនៅចំពោះមុខអង្គបុរេជំនុំជម្រះ និងអង្គជំនុំជម្រះតុលាការកំពូល និងខកខានក្នុងការបង្ហាញមូលហេតុ ដែលពុំតម្រូវឱ្យអនុវត្តតាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង ០០៤/២ និងកំហុសនៅក្នុងសំអាងហេតុ

---

[1] សំណើរបស់ មាស មុត សុំបញ្ចប់សំណុំរឿង ០០៣ ឯកសារលេខ 4 ថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០២១ ដែលបានជូនដំណឹងនៅថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០២១ ("សំណើសុំបញ្ចប់") កថាខណ្ឌ ៥២ ដល់ ៥៦, ៦១, ៦៥ និង ៧២។

[2] សារណាតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសំណើរបស់ មាស មុត សុំបញ្ចប់សំណុំរឿង ០០៣ ឯកសារលេខ 4/1 ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០២១ កថាខណ្ឌ ៥៥។

ឬការប្រែប្រួលនូវកាលៈទេសៈដែលតម្រូវឱ្យអង្គជំនុំជម្រះតុលាការកំពូលធ្វើយុត្តិកម្មក្នុងការសម្រេចក្នុងសំណុំរឿង ០០៣ ផ្សេងនោះឡើយ[3]

5. **រំឭក**សេចក្តីសម្រេចរបស់អង្គជំនុំជម្រះលើបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ អំពីការខកខានរបស់អង្គបុរេជំនុំជម្រះក្នុងការបញ្ជូនសំណុំរឿង ០០៣ ទៅជំនុំជម្រះដូចបានតម្រូវដោយក្របខ័ណ្ឌគតិយុត្តិរបស់ អ.វ.ត.ក. ដែលបានចេញនៅថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០២១ ក្នុងនោះបានសន្និដ្ឋានថា "ដោយសារគ្មានដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលអាចអនុវត្តបាន និងជាក់លាក់ សំណុំរឿង ០០៣ ត្រូវបានបញ្ចប់"[4]

6. **កត់សម្គាល់**លើមតិជំទាស់របស់ចៅក្រម Maureen Harding Clark ដែលថា ដោយសារពុំមានអត្ថប្រយោជន៍តម្រូវក្នុងការបង្វិលសេចក្តីសម្រេចដែលមានកំហុសនោះទៅឱ្យអង្គបុរេជំនុំជម្រះធ្វើការពិចារណាឡើងវិញ ទើបដើម្បីអត្ថប្រយោជន៍យុត្តិធម៌តម្រូវថា រឿងក្តី ០០៣ នេះគប្បីត្រូវបញ្ចប់[5]

7. អាស្រ័យហេតុនេះ**ពិចារណាឃើញ**ថា សំណើសុំបញ្ចប់រឿងក្តីនេះ លែងមានភាពចាំបាច់ក្នុងការពិចារណាបន្ថែមទៀត

**អាស្រ័យហេតុ÷**

**សម្រេច**ថា មិនទទួលពិចារណាលើសំណើរបស់ មាស មុត សុំបញ្ចប់សំណុំរឿង ០០៣ នេះឡើយ។

**រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០២១**

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

**គង់ ស្រ៊ឹម**

---

[3] ការឆ្លើយតបរបស់ មាស មុត ទៅនឹងសារណាតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសំណើរបស់ មាស មុត សុំបញ្ចប់សំណុំរឿង ០០៣ ឯកសារលេខ 4/1/1 ថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០២១ កថាខណ្ឌ ១ និង ៣។

[4] សេចក្តីសម្រេចនៃសំណុំរឿង ០០៣ ឯកសារលេខ 3/1/1/1 កថាខណ្ឌ ៤៤។

[5] សេចក្តីសម្រេចនៃសំណុំរឿង ០០៣ មតិជំទាស់របស់ចៅក្រម Maureen Harding CLARK ឯកសារលេខ 3/1/1/1 កថាខណ្ឌ ៨១ ដល់ ៨២។